ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សិក្ខាសាលា

## ក្រុមប្រឹក្សាបច្ចេកទេសលើកទី៩ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧

រៀបចំដោយៈ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន

នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឧបត្ថម្ភដោយៈ ថវិកាជាតិ

## ១. សេចក្តីផ្តើម

នៅព្រឹកថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៩ សម្រាប់ឆ្នាំ២០១៧ ក្រោមការដឹកនាំរបស់**ឯកឧត្តមវេជ្ជបណ្ឌិត តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅបន្ទប់ប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការអញ្ជើញចូលរួមមកពីតំណាងក្រសួង-ស្ថាប័នព្រមទាំងតំណាងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើការងារមេរោគអេដស៍ និងជំងឺអេដស៍។ កិច្ចប្រជុំនេះទទួលបានការឧបត្ថម្ភពីថវិកាជាតិ។

## ២. គោលបំណងនៃកិច្ចប្រជុំ

ដើម្បីបង្ហាញពីរបាយការណ៍វឌ្ឍនភាព សមិទ្ធផល និងទិសដៅបន្តក្នុងការឆ្លើយតបទៅនឹងការរីករាលដាលមេរោគអេដស៍ ព្រមទាំងពិភាក្សាសម្របសម្រួលការងារបច្ចេកទេសតាមរបៀបវារៈ ដូចខាងក្រោម៖

- មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំ
- របាយការណ៍ប្រចាំខែ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- បទបង្ហាញពីការដាក់បញ្ចូលការឆ្លើយតបចំពោះមេរោគអេដស៍ និងជំងឺអេដស៍ ទៅក្នុងផែនការអភិវឌ្ឍ និងផែនការវិនិយោគឃុំ-សង្កាត់។
- របាយការណ៍វឌ្ឍនភាពរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សម្រាប់បង្ហាញក្នុងកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០១៧។
- បទបង្ហាញពីផែនការសកម្មភាពសម្រាប់រៀបចំក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ឆ្នាំ២០១៧ និងសម្រាប់ប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០១៧។
- បញ្ហាផ្សេងៗ។

## ៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមវេជ្ជបណ្ឌិត តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានមានមតិស្វាគមន៍ និងថ្លែងអំណរគុណ ដល់សមាជិក-សមាជិកា ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ ដែលបានអញ្ជើញចូលរួមនាពេលនេះ ហើយកិច្ចប្រជុំនឹងប្រព្រឹត្តទៅតាមរបៀបវារៈដែលបានគ្រោងទុក។

<u>ប្រធានបទទី១៖</u> **ឯកឧត្តមវេជ្ជបណ្ឌិត ងារ ប៉ោ** អគ្គលេខាធិការរង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានជម្រាបជូនពីរបាយការណ៍សង្ខេប របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានអនុវត្តនៅក្នុងខែតុលា ឆ្នាំ២០១៧ ដូចខាងក្រោម៖



- នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៧ នៅសាលាខេត្តត្បូងឃ្មុំ ឯកឧត្តមអគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានអញ្ជើញជាគណៈអធិបតីក្នុងកិច្ចប្រជុំគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត និងបានចុះពិនិត្យស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងខេត្តត្បូងឃ្មុំផងដែរ។

- នារសៀលថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៧ នៅទីស្នាក់ការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ការងាររួមរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ក្នុងប្រទេសកម្ពុជា។

- ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៧ អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចូលរួមជាអធិបតីព្រមទាំងធ្វើបទបង្ហាញ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រស្តីពីការថែទាំ និងគាំទ្រដល់គ្រួសារក្រីក្រផ្ទុកមេរោគអេដស៍សម្រាប់ឆ្នាំ២០១៨របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

- ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧ អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំលើកទី២ ជាមួយអង្គការដៃគូ ដើម្បីត្រៀមរៀបចំពិធីបើកយុទ្ធនាការអប់រំផ្សព្វផ្សាយពីមេរោគអេដស៍ និងជំងឺអេដស៍ និងការប្រគំតន្ត្រីក្នុងឱកាសព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ឆ្នាំ២០១៧។

- នៅព្រឹកថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ នៅខេត្តបាត់ដំបង ឯកឧត្តមអគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចូលរួមដឹកនាំ និងសម្របសម្រួលកិច្ចប្រជុំ ដើម្បីពិនិត្យមើលលទ្ធផលការងារ៦ខែដើមឆ្នាំ២០១៧របស់ក្រុមការងារថ្នាក់ក្រោមជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់។

- នាថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ និយ័តករទូរគមនាគមន៍កម្ពុជា បានអន្តរាគមន៍ស្នើសុំដល់ប្រតិបត្តិករក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទចល័តទាំងអស់ ជួយផ្ញើសារ SMS អប់រំផ្សព្វផ្សាយពីមេរោគអេដស៍ និងជំងឺអេដស៍ តាមរយៈទូរស័ព្ទដៃ ក្នុងឱកាសព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ឆ្នាំ២០១៧ និងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០១៧ ក្នុងគោលបំណងដើម្បីជួយទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍។

- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានសហការជាមួយក្រសួងផែនការ អង្គការ UNDP និង UNAIDS បានឯកភាពគ្នាយកថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧ ដើម្បីរៀបចំពិធីចុះសួរសុខទុក្ខគ្រួសាររងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងជំងឺអេដស៍ នៅឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបង ដើម្បីបញ្ជាក់ពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល។

- ពីថ្ងៃទី១៧-២០ ខែតុលា ឆ្នាំ២០១៧ អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចុះអភិបាល និងពិនិត្យស្ថានភាពការងារឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅខេត្តពោធិ៍សាត់។ ក្នុងការចុះអភិបាលនោះ ក្រុមការងារបានជួបប្រជុំពិភាក្សាជាមួយប្រធានលេខាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត ការិយាល័យប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត ក្រុមប្រឹក្សាសង្កាត់លលាបសង្កាត់ផ្ទះព្រៃ និងជាមួយអង្គការ MHSS & PFD ស្ថិតនៅក្រុងពោធិ៍សាត់ ដើម្បីពិនិត្យមើលពីសកម្មភាពការងារដែលបានអនុវត្តកន្លងមក និងបញ្ហាប្រឈមនានាពិសេសទាក់ទងនឹងថវិកា។ ចំណែកអង្គការទាំងពីរនឹងអស់ថវិកាសម្រាប់អនុវត្តសកម្មភាពនៅបណ្តាច់ឆ្នាំនេះ។

- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំជាតិ ស្តីពីការបង្ការមេរោគអេដស៍ជាសកលសម្រាប់ស្ថាប័នមិនមែនវិស័យសុខាភិបាល។

- នៅព្រឹកថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០១៧ ឯកឧត្តមអគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានអញ្ជើញចុះផ្សព្វផ្សាយខ្លឹមសារនៃកិច្ចពិភាក្សាទស្សនៈយុវជន ស្តីអំពី "យុវជនកម្ពុជារួមចំណែកឈានឆ្ពោះទៅបញ្ចប់អេដស៍" ដល់សាកលវិទ្យាល័យន័រតុន និងសាកលវិទ្យាល័យវេស្ទើន ដែលមានអ្នកចូលរួមក្នុងមួយសាកលវិទ្យាល័យចំនួន២០០នាក់។

- ព្រឹកថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ នៅរាជធានីភ្នំពេញ ឯកឧត្តមអគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចូលរួមជាគណៈអធិបតីក្នុងមហាសន្និបាតរបស់បណ្តាញចតុមុខ

ដែលមានអ្នកចូលរួមចំនួន១០០នាក់ នៃក្រុមបណ្តាញ និងពេលរសៀល ឯកឧត្តមបានអញ្ជើញចូលរួមវគ្គបណ្តុះបណ្តាលតម្រង់ទិសកិច្ចពិភាក្សាទស្សនៈយុវជន ស្តីអំពី"យុវជនកម្ពុជារួមចំណែកឈានឆ្ពោះទៅបញ្ចប់អេដស៍" នៅទីស្នាក់ការកណ្តាលកាកបាទក្រហមកម្ពុជា ដែលមានអ្នកចូលរួម ៣៤ នាក់។

- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានសម្របសម្រួលលិខិតទៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងព័ត៌មាន ដើម្បីស្នើសុំជួយផ្សព្វផ្សាយសារអប់រំមេរោគអេដស៍និងជំងឺអេដស៍និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈដើម្បីឱ្យសិល្បៈករជួយអប់រំផ្សព្វផ្សាយ។

**<u>ផែនការសកម្មភាព និងទិសដៅបន្ត៖</u>**

- បន្តតាមដានសម្រាប់ព្រឹត្តិការណ៍៖
  - ✓ ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ឆ្នាំ២០១៧
  - ✓ កិច្ចប្រជុំពេញអង្គលើកទីពីរ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សម្រាប់ឆ្នាំ២០១៧
  - ✓ សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៧ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
  - ✓ ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ ធ្នូ ឆ្នាំ២០១៧។
- បន្តរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំជាតិ ស្តីពីការបង្ការមេរោគអេដស៍ជាសកលសម្រាប់ស្ថាប័នមិនមែនវិស័យសុខាភិបាល។



**ប្រធានបទទី២៖** បទបង្ហាញការពិគ្រោះយោបល់ ស្ដីពីការរៀបចំនិយាមប្រតិបត្តិសម្រាប់ការធ្វើសមាហរណកម្ម ការឆ្លើយតបចំពោះមេរោគអេដស៍ និងជំងឺអេដស៍ ទៅក្នុងផែនការអភិវឌ្ឍ និងផែនការវិនិយោគឃុំ-សង្កាត់ ដោយ **ឯកឧត្តមវេជ្ជបណ្ឌិត ទា ផលា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍៖

- **<u>ក្នុងគោលបំណង៖</u>** ពង្រីក និងពង្រឹងតួនាទីរបស់មណ្ឌលសុខភាព និងឃុំសង្កាត់ ដើម្បីចូលរួមក្នុងការលុបបំបាត់មេរោគអេដស៍ឱ្យបាននៅឆ្នាំ២០២៥ នៅតាមមូលដ្ឋាន។
- **<u>គោលបំណងជាក់លាក់គឺ៖</u>**
  - ✓ យន្តការមុខងារ និងការទទួលខុសត្រូវរបស់មណ្ឌលសុខភាព គណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព ក្រុមប្រឹក្សាឃុំ គណៈកម្មាធិការឃុំដើម្បីស្ត្រី និងកុមារ។
  - ✓ សមត្ថភាពរបស់មណ្ឌលសុខភាព និងក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងការលុបបំបាត់មេរោគអេដស៍ និងជំងឺអេដស៍។
  - ✓ រៀបចំផែនការដើម្បីធានាឱ្យមានថវិកាសម្រាប់ឃុំ-សង្កាត់ ចូលរួមលុបបំបាត់មេរោគអេដស៍ និងជំងឺអេដស៍។
  - ✓ ភាពជាដៃគូ និងការសម្របសម្រួលរបស់មណ្ឌលសុខភាព និងក្រុមប្រឹក្សាឃុំ-សង្កាត់ ចូលរួមក្នុងការលុបបំបាត់មេរោគអេដស៍ និងជំងឺអេដស៍។
- **<u>ហេតុផល</u> (ការប្ដេជ្ញាចិត្ត និងស្ថានភាព)៖**
  - ✓ RGC ប្ដេជ្ញាសម្រេចគោលដៅ៩០-៩០-៩០ និង៩៥-៩៥-៩៥ និងការលុបបំបាត់មេរោគអេដស៍ និងជំងឺអេដស៍ នៅឆ្នាំ២០២៥។
  - ✓ មិនទុកនរណាម្នាក់ចោលទេ( No one left behind )។
  - ✓ បន្ទុកការងារលើការថែទាំព្យាបាលអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ កាន់តែកើនឡើងសម្រាប់ ក្រុមគ្រូពេទ្យ។
  - ✓ ជំនួយដៃគូអភិវឌ្ឍសម្រាប់ការឆ្លើយតបទៅនឹងមេរោគអេដស៍ ត្រូវបានកាត់បន្ថយជាលំដាប់។
  - ✓ និយាម CBPCS និងវិធីសាស្ត្រសហគមន៍សម្រាប់អនុវត្តវិធីសាស្ត្រ BIACM ត្រូវបានដាក់ឱ្យអនុវត្ត។
- **<u>ផ្នែកសំខាន់ៗដែលត្រូវវិភាគ៖</u>**
  - ✓ យន្តការ មុខងារ និងការទទួលខុសត្រូវ
  - ✓ សមត្ថភាព

- ✓ ការរៀបចំផែនការ និងថវិកា
- ✓ ភាពជាដៃគូ និងកាសម្របសម្រួល។

➢ **បញ្ហាប្រឈម៖**

- ✓ HCMC មិនបានចូលរួមប្រជុំប្រចាំខែគ្រប់គ្នាតាមការកំណត់ ដោយសារគាត់រវល់ការងារ។
- ✓ ឃុំ-សង្កាត់មិនទាន់ម្ចាស់ការក្នុងការលើកផែនការកញ្ចប់ថវិការដ្ឋ ដោយសាថវិកាមូលនិធិឃុំ-សង្កាត់ មានកំណត់ ពេលអង្គការដៃគូបញ្ចប់គម្រោង។

**ប្រធានបទទី៣៖** បទបង្ហាញពីផែនការសកម្មភាពសម្រាប់រៀបចំក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ឆ្នាំ២០១៧ និងសម្រាប់ប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ ធ្នូ ឆ្នាំ ២០១៧ ដោយ **ឯកឧត្តមវេជ្ជបណ្ឌិត ជា ប៉ោ** អគ្គលេខាធិការរង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍៖

➢ ពិធីបើកយុទ្ធនាការអប់រំផ្សព្វផ្សាយពីមេរោគអេដស៍ និងជំងឺអេដស៍ ធ្វើនៅមុខអគារអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ វេលាម៉ោង២រសៀល ដោយមានអ្នកចូលរួម ១00នាក់(ថ្នាក់ដឹកនាំNAA PAC PAS រាជធានីភ្នំពេញ អាជ្ញាធរមូលដ្ឋានខណ្ឌទួលគោក ខណ្ឌដូនពេញ យុវជនNAA និងយុវជនSTYDA អង្គការ KHANA PSK RHAC FHI AHF HACC WNU និងអ្នកសារព័ត៌មាន ទូរទស្សន៍) និងការប្រគំតន្ត្រីអប់រំផ្សព្វផ្សាយពីមេរោគអេដស៍ និងជំងឺអេដស៍ នៅត្រើយខាងកើតស្ពានជ្រោយចង្វារ (បរិវេណដីក្រុមហ៊ុនOCIC) រយៈពេល៣ថ្ងៃ (ថ្ងៃទី0២-0៤ ខែវិច្ឆិកា ឆ្នាំ២០១៧)។



➢ ការប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ ធ្នូ ឆ្នាំ២០១៧ នឹងរៀបចំនៅសាលសន្និសីទចតុមុខ នៅពេលព្រឹក និងការប្រគំតន្ត្រីផ្សព្វផ្សាយពីមេរោគអេដស៍ និងជំងឺអេដស៍ នៅពេលរសៀល។

ជាកិច្ចបន្ត **លោកវេជ្ជបណ្ឌិត ឆេព ឈារាឌុច** ប្រធាននាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ បានជម្រាបជូនថា គិតមកដល់ពេលនេះមានក្រសួងចំនួន៩ បានផ្ញើរបាយការណ៍មកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សម្រាប់ដាក់បញ្ចូលទៅក្នុងរបាយការណ៍រួម ដើម្បីបង្ហាញនៅក្នុងកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០១៧ និងសំណូមពរឱ្យក្រសួង-ស្ថាប័ន ទាំងអស់ផ្ញើរបាយការណ៍សកម្មភាពមកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឱ្យបានមុនថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៧។

ជាកិច្ចបន្ត ឯកឧត្តមប្រធានអង្គប្រជុំ បានជម្រាបជូនដល់សមាជិក-សមាជិកានៃអង្គប្រជុំថា **កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១០ នឹងប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៧** ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង១១ និង២០នាទី ថ្ងៃ ខែ ឆ្នាំ ដដែល ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាលបំផុត៕

**<u>ឧបសម្ព័ន្ធ៖</u>**

- បញ្ជីវត្តមានអ្នកចូលរួម
- ឯកសារបទបង្ហាញផ្សេងៗ

ភ្នំពេញ ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៧

បានឃើញ និងឯកភាព

**អគ្គលេខាធិការ**

វេជ្ជ.តែង គន្ធី

**ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន**

លាង សិរី

បានឃើញ

សាស្ត្រាចារ្យ លី ម៉ី 7/11/17